# Living the Lotus

4
2022

Buddhism in Everyday Life

VOL. 199





**Living the Lotus**
**Vol. 199 (April 2022)**

Senior Editor: Keiichi Akagawa
Editor: Jigjidkhorloo Gereltuya
Copy Editor: Penn Setharin
*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international
@kosei-kai.or.jp


រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

# សញ្ញានៃការដឹងគុណនៃយើងម្នាក់ៗ----កាន់សីល

ព្រះសង្ឃនីវ៉ាណូ និជិកុ
ព្រះប្រធានរីហ្សូកូសេកៃ



## ពាក្យថា 《 ដោយសារគុណបុណ្យអ្នកទាំងអស់គ្នា》 ---គឺជាការដឹងគុណជាមូលដ្ឋាន

អាត្មាភាពតែងតែនិយាយជារឿយៗមកហើយថា តាំងពីយើងកើតឡើងមករហូតមកដល់ថ្ងៃនេះ យើងទាំងឡាយត្រូវបានពង្រស់ដោយសារ 《គុណបុណ្យ》 នៃអ្វីៗនានាដ៏ច្រើន ក៏ប៉ុន្តែបើឱ្យសួរថា តើរាល់ថ្ងៃយើងដែលនឹកឃើញថ្លែងអំណរគុណទៅអ្វីៗទាំងនោះឬទេ?ប្រាកដជាអ្នកដែលហ៊ានលើកដៃឆ្លើយយ៉ាងសង្ហាថា 《បាទ》 ឬ《ចាស》 មិនមានច្រើនទេ។មិនត្រឹមតែមិនមានទេ អាចមានដល់ទៅអ្នកដែលខឹងសម្បារនឹងអាកាសធាតុ ឬមិនអាចនិយាយពាក្យ《 អរគុណ》 ទៅកាន់មនុស្សក្នុងគ្រួសារទៅទៀតក៏មានដែរ។

នៅក្នុងបារមីទាំង៦ (ព្រះពុទ្ធសាសនាមហាយានមានតែបារមី៦ទេ) មានបារមីមួយគឺ 《សីលបារមី》 (បើមើលតាមន័យអក្សរចិនគឺត្រូវកាន់វិន័យ) ។ភាសាដើមជាភាសាសំស្ក្រឹត គឺ《សីលា》 មានន័យថាប្រព្រឹត្តទម្លាប់ល្អជាប្រចាំ។ សីលបារមីនេះ គឺហាក់ដូចជាបំរាម ហាមធ្វើនេះហាមធ្វើនោះក៏ប៉ុន្តែតាមការពិតជាសេចក្តីប្រាថ្នានៃព្រះពោធិសត្វដែលចង់ឱ្យទាំងខ្លួនឯងទាំងអ្នកដទៃមានសេចក្តីសុខ សុភមង្គលដែលមានន័យវិជ្ជមានទេ។

ចំណុចនេះពាក់ព័ន្ធខ្លាំងទៅនឹងអ្វីដែលអាត្មាភាពនិយាយអំបាញមិញគឺ<យើងម្នាក់ៗត្រូវបានពង្រស់ដោយ 《គុណបុណ្យ》 នៃអ្វីៗនានាដ៏ច្រើន>ដែលជាមូលដ្ឋានគ្រឹះនៃព្រះពុទ្ធសាសនា។យើងត្រូវតែដឹងគុណចំពោះអ្វីៗនានាដ៏ច្រើនដែលបានធ្វើឱ្យយើងរស់។ដូច្នេះហើយយើងតោងតែធ្វើយ៉ាងណាឱ្យអ្នកទាំងឡាយនោះមានសេចក្តីសុខសេចក្តីសប្បាយ។នេះហើយជាសេចក្តីប្រាថ្នានៃព្រះសម្មាសម្ពុទ្ធហើយជាទិសដៅដែលព្រះពោធិ

សត្វសំដៅទៅរក។ការតបស្នងទៅវិញចំពោះ《គុណបុណ្យនៃអ្វីៗទាំងឡាយ》ដ៏ច្រើននេះគឺមានតែផ្តល់ភាពកក់ក្តៅដល់មនុស្សឬអ្វីដែលនៅជុំវិញខ្លួនតាមដែលអាចធ្វើបានតែប៉ុណ្ណោះ។ទោះជានៅទីណាក្តី ដើមដំបូងឡើយ អ្វីៗទាំងអស់មានភាពសុខដុំរម្យនាជាមួយគ្នានឹងគ្នា ហើយនេះជាច្បាប់ធម្មជាតិ។ ម្នាក់ៗតោងតែប្រត្តិបត្តទម្លាប់ធ្វើឱ្យអ្នកទាំងឡាយសប្បាយជាមួយគ្នា។នេះហើយគឺជាការបង្ហាញនូវទឹកចិត្តដឹងគុណចំពោះអ្វីៗដែលបានពង្រស់ខ្លួនឱ្យមានជីវិតពោលគឺប្រត្តិបត្ត សីលបារមី ដែលជាទង្វើនៃព្រះពោធិសត្វ។

សីលដែលឧបាសក ឧបាសិកាអ្នកសុំសីលនៅផ្ទះមាន៥ គឺមិនសម្លាប់ មិនលួច មិនប្រព្រឹត្តកាមមិនត្រឹមត្រូវ មិននិយាយអាក្រក់ភូតកុហក មិនទទួល ទានស្រា។បើយើងមើលទៅទស្សនៈ

ទាំងឡាយនេះ សីល៥ គឺជាពាក្យប្រៀនប្រដៅកុំឱ្យបង្កទុក្ខទោសដល់អ្នកដទៃ មិនធ្វើឱ្យគេមានរបួសទាំងកាយទាំងចិត្ត ។គោរពជីវិតគ្រប់យ៉ាង ពង្រស់ និងរស់ដោយសុខដុំរម្យនាសប្បាយរីករាយជាមួយគ្រួសារ ញាតិមិត្ត ------ទាំងនេះគឺជាសេចក្ដីរីក
រាយបំផុតរបស់ខ្លួនផងដែរ។

## ម្នាក់ៗត្រូវបង្កើត《ការកាន់សីលផ្ទាល់ខ្លួនមួយ》

សាស្ត្រាចារ្យម៉ូរី ម៉ាសាហ៊ីរ៉ូ ដែលជាអ្នកជំនាញខាងរ៉ូបូ ហើយជាអ្នកយល់ដឹងពីព្រះពុទ្ធសាសនាជ្រៅជ្រះ បានមានប្រសាសន៍ថា ៖ ដូចមុខមនុស្សដែលខុសគ្នាដូច្នេះដែរ មនុស្សម្នាក់ៗមានលក្ខណៈពិសេសនិងចំណុចខ្សោយខុសៗគ្នារៀងៗខ្លួន ដូច្នេះសីល ក៏នឹងខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ដែរ។ពោលគឺថា យើងអាចបង្កើតទម្លាប់ល្អ =ការកាន់សីល សម្រាប់ខ្លួនយើងម្នាក់ហើយប្រត្តិបត្តិ។នេះគឺអ្វីដែលសំខាន់។

ដូច្នេះចូរយើងគិតទៅថាតើអ្វីដែលជាទម្លាប់ចាំ បាច់រួមទាំងសីល៥ផង ចំពោះយើង។ឧទាហរណ៍ ប្រសិនបើយើងជាមនុស្សដែលតែងតែទៅមិនទាន់ពេលណាត់ ឬសន្យា ជានិច្ចជាកាល ហើយតែងតែធ្វើឱ្យអ្នកដទៃអំពល់ទុក្ខ យើងខំធ្វើយ៉ាងណាឱ្យទៅដល់កន្លែងណាត់មុន៥នាទីឬ១០នាទី។នេះជាពាក្យសម្ដីដែលព្រះគ្រូស្ថាបនិកកៃសូសាម៉ាលោកតែងមានពុទ្ធដិកាជារឿយៗ។រីឯអ្នកដែលឆាប់ខឹង ត្រូវបង្កើតទម្លាប់នៅពេលរកខឹង ត្រូវរំលឹកពាក្យថា៖នៃភាពញញឹម ខ្ញុំមិនខឹងទេ ហើយទន្ទេញពាក្យនេះដោយដកដង្ហើមវែងៗ ។

ទម្លាប់នេះនឹងអាចជួយឱ្យអ្នកចៀសវាងធ្វើឱ្យអ្នកនៅក្បែរខ្លួនមិនសប្បាយចិត្តបាន។

ជាការពិតណាស់ មនុស្សសុទ្ធតែខុសៗគ្នា ដូច្នេះរបៀបកាន់សីលក៏ខុសគ្នា ។យើងអាចគិតថាការកាន់សីល គឺជាវិន័យនៃការរស់នៅ ហើយខុសពីវិន័យបន្តិចត្រង់ថានៅក្នុងចិត្តមនុស្សម្នាក់ៗត្រូវមានអំណរគុណចំពោះ《គុណ្យបុណ្យនៃអ្វីៗទាំង ឡាយ》ព្រមទាំងសេចក្ដីប្រាថ្នាចង់រស់នៅដោយសុខដុំរម្យនាជាមួយនឹងអ្នកដទៃ។នៅពេលដែលបេះដូងគិតពីអ្នកដទៃដោយបង្កភាព
សុខដុំរម្យនា ឥរិយាបទនោះបន្តផ្ទាប់ទៅនឹងសេចក្ដីសប្បាយរីករាយរបស់ខ្លួនឯងផ្ទាល់ដែលត្រូវនឹងសេចក្ដីព្យា យាមរបស់ព្រះពោធិសត្វ។

គេច្រើននិយាយថា៖នៅប្រទេសដែលមានព្រឹលធ្លាក់ រដូវផ្ការីកចូលមកតាមគល់ឈើ។ស្ថានភាពដែលព្រឹលរលាយនៅគល់ឈើមុនកន្លែងណាៗនោះគេហៅថា《ព្រឹលបើកគល់ឈើ》។បើយើងគិតពីរដូវផ្ការីកនៅស្រុកកំណើតរបស់ព្រះគ្រូស្ថាប និកកៃសូសាម៉ា គឺ ស៊ីង៉ានុម៉ា នៅក្នុងព្រឹលដែលសេសសល់លើផ្ទៃពសុធា យើងនឹងបានទៅដល់ការចងចាំដ៏រាបសាពីផ្កាសាគូរ៉ានៃព្រះអង្គជីងយូដែលជាទេវតារក្សាទឹកដីដែលចាប់ផ្ដើមរីកយ៉ាងត្រចះត្រចង់។

យើងទាំងអស់គ្នាថ្លែងអំណរគុណចំពោះព្រះពុទ្ធជាម្ចាស់ដែលបានគូសវាសនូវអ្វីទាំងនេះ ហើយបង្កទម្លាប់ឃោលទៅតាមច្បាប់ធម្មជាតិ រស់នៅដោយសុខដុំរម្យនាជានិច្ចជាកាល។

『ទស្សនាវត្ដីកូសេ』លេខខែ៤ ឆ្នាំ២០២២

# ជីវិតរបស់ខ្ញុំបានផ្លាស់ប្តូរដោយសារការបង្រៀនពាក្យថា៖ គិតអ្នកដទៃជាចំបង

ខ្ញុំឈ្មោះរឿន ចំណាប់ ទីកន្លែងការិយាល័យហូហ្សាក់ភ្នំពេញ កម្ពុជា

សូមគោរពអ្នកទាំងអស់គ្នា!

ខ្ញុំឈ្មោះ រឿន ចំណាប់ ជាសមាជិកពេញសិទ្ធនៅការិយាល័យហូហ្សាក់ភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា

ឪពុករបស់ខ្ញុំគាត់ឈ្មោះ ជា សារឿន ម្តាយរបស់ខ្ញុំគាត់ឈ្មោះ ប៉ូច យឿម ខ្ញុំជាកូនទី២ កើតនៅថ្ងៃទី ២៦ខែកក្កដាឆ្នាំ ១៩៨៦ ទីកន្លែងកំណើតនៅខេត្តបាត់ដំបងជាផ្នែកមួយនៃព្រះរាជាណាចក្រកម្ពុជា ដែលឃ្លាតពីទីក្រុងភ្នំពេញប្រហែលជា ៣០០គីឡូម៉ែតជាង។ ខ្ញុំមានបងប្អូនបង្កើត បងប្រុស និង ប្អូនស្រី ម្តាយផ្សេងៗគ្នា។ ក្រោយបញ្ចប់ការសិក្សានៅ ជាសិស្សបរទេសនៅហ្គាគីរីននៅខែមីនា ឆ្នាំ២០១៤ មក បច្ចុប្បន្ននេះខ្ញុំកំពុងបំរើការនៅក្រុមហ៊ុនអចលនទ្រព្យជប៉ុន។

ខ្ញុំជាជំនួយការផ្ទាល់របស់លោកនាយកក្រុមហ៊ុន ហើយមិនត្រឹមតែជាអ្នកបកប្រែប៉ុណ្ណោះទេ ថែមទាំងគ្រប់គ្រងការងារទូទៅ ការគ្រប់គ្រងហិរញ្ញវត្ថុ និង គ្រប់គ្រងលទ្ធកម្មសម្ភារៈ និង ជាអ្នកគ្រប់គ្រងអាជីវកម្មទូទៅរបស់ក្រុមហ៊ុនផងដែល។

ដោយសារតែនៅក្នុងក្រុមហ៊ុនបុគ្គលិកដែលចេះភាសាជប៉ុនមានខ្ញុំម្នាក់ ដូច្នេះហើយមានការងារជាច្រើនដែលលោកនាយកពឹងពាក់អោយធ្វើ វារវល់ពិតមែនតែខ្ញុំមានចិត្តសប្បាយទទួលរាល់ការងារទាំងអស់ធ្វើវា។ ខ្ញុំមានឧប្បនិស័យជា អង្គារ រីស្សូកូសេកៃ នៅឆ្នាំ២០០៩ នៅពេលនោះ ខ្ញុំជាបុព្វជិតបានបួសសិក្សារៀនសូត្រនៅវត្តមួយជិតទីក្រុងភ្នំពេញ មានសិស្សច្បងជាព្រះសង្ឃ មួយអង្គ គឺព្រះនាម សុខដាលីន (ឥលូវលោកបានលាចាកសិក្ខាបទហើយ) បានបបូលខ្ញុំអោយចូលរួមកម្មពិធីប្រជុំរបស់អង្គារ រីស្សូកូសេកៃ។ ការប្រជុំនៅពេលនោះ មានមន្ត្រីផ្ទាល់ខាងការិយាល័យកណ្តាល ( ក្នុងពេលនោះ គណកម្មាធិការ អប់រំ) ក្នុង១ឆ្នាំគាត់បានមកបង្រៀនជាច្រើនដងនោះ គឺជាលោក （Rev. Reiji Umetsu）

គាត់បាននិយាយឬប្រាប់អំពីផ្លូវដើរមានសុភមង្គលដល់ពួកយើង ពេលនោះក្រោយពីការបង្រៀនខ្ញុំបានទទួលពាក្យ (គិតអ្នកដទៃជាចំបង) គឺខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។

ខ្ញុំគិតថាមានមនុស្សជាច្រើនបានដឹងរឿងនោះ គឺសង្គ្រាមផ្ទៃក្នុងចាប់ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៩៣ ជាបទពិសោធន៍ដ៏ជូរចត់។ ក្នុងអំឡុងពេលដ៏យូរមនុស្សម្នាត្រូវបានបោះបង់ផ្ទះសម្បែងចោលដោយសារសង្គ្រាម មុនពេលប្រជាជនកម្ពុជាដឹង

ហើយខ្ញុំមានអារម្មណ៍ថាដើម្បីរស់រានមានជីវិត គឺមិនបានគិតពីអ្នកដ៏ទៀតសោះឡើយ ហើយប្រសិនបើអ្នកពិចារណាពីអ្នកដ៏ទៃ គិតថាមិនសូវមានជីវិតរស់ច្រើនឡើយ។ ដោយសារមេរៀនបែបនេះហើយ ធ្វើអោយចិត្តរបស់ខ្ញុំមានអារម្មណ៍សប្បាយដែលអធិប្បាយដោយលោក Reiji Umetsu មានទឹកចិត្តជ្រះថ្លាណាស់សម្រាប់ការផ្តល់ដំបូលមាន ដែលធ្វើអោយខ្លួនមានសុភមង្គល ដោយពាក្យ គិតអ្នកដ៏ទៃជាចំបង គឺវាមានអារម្មណ៍ថាសំខាន់ណាស់។ បន្ទាប់ពីបទពិសោធន៍នេះ

រាល់ពេលលោក Reiji Umetsu មកប្រទេសកម្ពុជាម្តងៗ ខ្ញុំបានសិក្សាអំពីការបណ្តោះបណ្តាលរបស់អង្គារ រីស្សូកូសេកៃ ជាពិសេសគឺការប្រតិបត្តិនៃការបង្រៀនរបស់ព្រះសម្មាសម្ពុទ្ធ



*កន្លែងធ្វើការ (ភ្នំពេញ)*

បរមគ្រូ។ នៅក្នុងសភាពបែបនេះ ខ្ញុំទទួលឪកាសធ្វើដំណើរទៅសិក្សានៅ ហ្គាគីរីន នៃប្រទេសជប៉ុនបន្ថែមទៀត។

តាមពិតទៅ ខ្ញុំនិងឪពុករបស់ខ្ញុំមិនសូវមានទំនាក់ទំនងល្អទេ ក្នុងសម័យសង្គ្រាមស៊ីវិលឪពុកខ្ញុំត្រូវបានជ្រើសរើសធ្វើជាទាហាន គ្រួសាររបស់ពួកយើងត្រូវបានគេនាំយកមកមាតុភូមិវិញ។ ទោះបីជាសង្គ្រាមស៊ីវិលបានបញ្ចប់យ៉ាងយូរក៏ដោយ តែមិនឃើញឪពុកខ្ញុំត្រឡប់មកផ្ទះសោះ ម្តាយខ្ញុំនិងបងប្អូនខ្ញុំបានគិតថាឪពុកបានស្លាប់ហើយ។ មានថ្ងៃមួយឪពុកខ្ញុំបានត្រឡប់មកផ្ទះវិញ ពួកយើងដំបូងមានអារម្មណ៍ថាសប្បាយចិត្តខ្លាំងណាស់ ប៉ុន្តែ ខ្ញុំបាននឹកឃើញអាក្រក់ក្នុងសង្គ្រាមស៊ីវិល ឪពុកខ្ញុំបានទុកគ្រួសារពួកយើងយូរដោយមិនខ្វាល់ ហើយខ្ញុំមិនសូវមានការសន្ទនាជាមួយគាត់ទេ។

ក្រោយពីបញ្ចប់សង្គ្រាមស៊ីវិលមក គ្រួសាររបស់ខ្ញុំមានជីវភាពក្រីក្រលំបាក នៅអាយុ១៣ឆ្នាំដើម្បីបន្តការសិក្សារខ្ញុំសាងផ្នួសជាព្រះសង្ឃបន្តមកសិក្សារនៅវត្តទីក្រុងភ្នំពេញ ខ្ញុំបានចាប់ផ្តើមជីវភាពនឹងសិក្សារបន្តើនៅទីនោះ។ ពេលក្លាយជាព្រះសង្ឃខ្ញុំត្រូវបានសិក្សារនៅសាលាពុទ្ធិកបឋមសិក្សារដែលជាសាលារបស់រដ្ឋហើយត្រូវបានលើកលេង បង់ថ្លៃសាលា ហើយបានការបរិច្ចាគទានពីពុទ្ធបរិស័ទចំណុះជើងវត្ត ដើម្បីបន្តជីវភាពបាន។ ប៉ុន្តែ សម្ភារៈសិក្សារវិញ គឺចាំបាច់ត្រូវរៀបចំដោយខ្លួនឯងទោះបីជាយ៉ាងណាគឺថាបច្ច័យវាចាំបាច់ណាស់។ ប៉ុន្តែបច្ច័យឪពុកផ្ញើអោយ ១ឆ្នាំគឺ២៥ដុល្លារ គឺចំនួនប៉ុណ្ណឹងវាមិនគ្រប់ទល់តែសោះ ហើយនៅពេលអត់បច្ច័យ គឺខ្ញុំបានឈប់ការទៅសាលា។

ទោះបីជាខ្ញុំមានរឿងមិនពេញចិត្តទាក់ទងជាមួយឪពុកយ៉ាងនេះក្តី មានពេលមួយ ខ្ញុំបានលឺដំណឹងពីសាច់ញាតិប្រាប់ថាឪពុកខ្ញុំគាត់បានមកលេងនៅភ្នំពេញ២សប្តាហ៍ ការខឹងរបស់ខ្ញុំពិតជាខ្លឹងខ្លាំងណាស់។

សាច់ញាតិខ្ញុំគឺគាត់រស់នៅខាងក្រោយវត្តដែលខ្ញុំកំពុងស្នាក់នៅ ឪពុកខ្ញុំគាត់មកទីនេះហើយ ហេតុអីមិនទាក់ទងមកខ្ញុំទល់តែសោះ។ ខ្ញុំបានប្រាប់ទៅសាច់ញាតិថា ខ្ញុំចង់ជួបគាត់សូមនាំគាត់មកវត្តផង ហើយគាត់ក៏បានមកវត្តតាមការណាត់មែន។ ខ្ញុំបានសួរឪពុកខ្ញុំ មកដល់ជិតវត្តហើយ ហេតុអីបានជាមិនមកលេងខ្ញុំ ពេលនោះគាត់អត់មានឆ្លើយអ្វីទល់តែសោះ។ ខ្ញុំមានអារម្មណ៍ឃ្លាន មានអារម្មណ៍ទុក្ខព្រួយ មានអារម្មណ៍ឯកា មានអារម្មណ៍ស្មុគស្មាញ ហើយខ្ញុំបានខឹងនឹងគាត់ខ្លាំង បើពុកមិនចាប់អារម្មណ៍និងខ្ញុំ សូមផ្តាច់និស្ស័យជាឪពុកកូននឹងត្រឹមហ្នឹងទៅ ។

ក្រោយពេលនោះមក ពេលខ្ញុំមានធុរៈទៅខេត្តបាត់ដំបងម្តងៗ ខ្ញុំមិនចង់ឃើញមុខឪពុកទេ ហើយក៏មមិនស្នាក់នៅផ្ទះដែរ ខ្ញុំបានទៅស្នាក់នៅវត្តជិតនឹងវិញ ហើយខ្ញុំបានគិតថាទំនាក់ទំនង និងគាត់គឺត្រូវបានចប់គ្នា។ ដូច្នេះហើយ ខ្ញុំមានអារម្មណ៍ស្អប់គាត់ ប៉ុន្តែនៅពេលសិក្សារសារៈសំខាន់នៃវិធីរំលឹកវិញ្ញាណក្ខន្ធដូនតា នឹងការគោរពបូជានៅ ហ្គាគីរីន បានប៉ះចំការបង្រៀនរបស់ស្ថាបនិកគិតអ្នកដទៃជាមុន ពេលនោះតើហេតុអីក្នុងចិត្តខ្ញុំគិតពីឪពុកខ្ញុំជានិច្ច។

នៅឆ្នាំ២០១២ ខ្ញុំបានមដល់ប្រទេសជប៉ុន ដើម្បីបន្តការសិក្សារនៅ ហ្គាគីរីន ពេលនោះចាប់ផ្តើមជីវភាពនៅទី



*ជាមួយលោកឪពុក(បាត់ដំបង)*

ក្រុងអ៊ូមេ របស់ទីក្រុងតូក្យូដែលមានហ្គាគីរីននៅទីនោះ។ ចំណាប់អារម្មណ៍ដំបូងរបស់ខ្ញុំពេលបានមកដល់ជប៉ុន គឺថាប្រទេសជប៉ុនស្រស់ស្អាត នៅជិតនឹងសូម្បីសំរាមក៏គ្មានជ្រុះ ហើយស្ទឹងនៅក្រោយអន្តេវាសិកដ្ឋានវិញគឺមិនក៏ខ្វាក់ទេ គឺឺវាមានតម្លាភាពណាស់។ លើសពីនេះទៅទៀត យើងបានស្នាក់នៅអន្តេវាសិកដ្ឋានជាមួយមនុស្សដែលមានវប្បធម៌ផ្សេងៗគ្នា ហើយពួកយើងបានជួយគ្នាទៅវិញទៅមកដើម្បីបំពេញភារកិច្ចសម្រាប់ការរស់នៅ។

នៅទីនោះយើងមានពិភពលោកដោយពាក្យ គិតអ្នកដទៃជាចំបង ដូច្នេះហើយខ្ញុំបានប្រតិបត្តការបង្រៀនពាក្យ គិតអ្នកដទៃ ទៅមនុស្សជាច្រើន ខ្ញុំបានដឹងថាពិភពលោកដ៏អស្ចារ្យបែបនេះ នឹងលេចឡើងនៅកន្លែងនេះ។

ដូចដែលការអនុវត្តនៅហ្គាគីរីន មកដល់ពេលនេះបានឆ្លុះបញ្ចាំអំពីអាកប្បកិរិយាដែលគិតតែពីខ្លួនឯង ។ ដូច្នេះហើយខ្ញុំបានគិតយ៉ាងខ្លាំងថា ត្រូវតែកែទំនាក់ទំនងល្អជាមួយឪពុកខ្ញុំវិញ។ មានថ្ងៃមួយខ្ញុំបានតាំងចិត្តខលទូរសព្ទ័ពីប្រទេសជប៉ុនដើម្បីនិយាយជាមួយគាត់។ អំឡុងនៅប្រទេសជប៉ុនខ្ញុំគិតពីពុករហូត ឥលូវនៅសល់តែពុកម្នាក់គត់ ខ្ញុំត្រូវតែគិតពុកជាធំ ពេលនិយាយជាមួយគាត់ខ្ញុំបានសួរគាត់ថា តើជីវភាពប្រចាំថ្ងៃយ៉ាងម៉េចហើយ? តើសុខភាពមិនអីទេឬ? គាត់បានឆ្លើយថាមិនអីទេ សុខទុក្ខធម្មតា ក្រោយស្ដាប់ហើយខ្ញុំមានអារម្មណ៍ថាសប្បាយចិត្ត ហើយគាត់បានសួរខ្ញុំវិញ កូនឯងរៀននៅជប៉ុនមានបញ្ហាអីអត់? ខ្ញុំបានប្រាប់គាត់វិញថាការសិក្សានៅទីនេះអត់អី។

ក្រោយបញ្ចប់ការសិក្សាខ្ញុំត្រឡប់មកប្រទេសកម្ពុជាវិញ ខ្ញុំបានចាប់ផ្ដើមថ្លែងអំណរគុណទៅឪពុក ហើយចាប់មានទំនាក់ទំនងល្អវិញជាមួយគាត់ សម្រាប់ខ្ញុំគឺជាកុសលដ៏ធំក្រៃលែង។ នៅឆ្នាំ២០១៥ ឪពុករបស់ខ្ញុំចង់រក្សាជីវិតរបស់គាត់ដែលនៅសេសសល់គាត់ក្នុងភាពសុខសាន្ត គាត់បានសាងព្រះផ្នួសជាព្រះសង្ឃ។ ខ្ញុំនៅពេលជាព្រះសង្ឃ គឺគាត់បានផ្ញើបច្ច័យសម្រាប់ថ្លៃចំណាយលើជីវិត ឥលូវវិញខ្ញុំបានផ្ញើបច្ច័យប្រគេនលោករាល់ខែផងដែរ។

[គិតអ្នកដទៃជាចំបង]

ខ្ញុំបានចាប់ផ្ដើមសិក្សារនៅពេលខ្ញុំមានឧបនិស្ស័យជាមួយអង្គការ កូសេកៃ បានទទួលការបង្រៀនរបស់លោកស្ថាបនិក ដូចមានពាក្យថា ឧបនិស្ស័យដំបង ហើយការបង្រៀននេះវាបានដកក្នុងចិត្តខ្ញុំជាលើកដំបូង ហើយពេលនេះវាបានក្លាយជាគោលដៅមួយដ៏សំខាន់សម្រាប់ជីវិតរបស់ខ្ញុំ។ នៅឆ្នាំ២០១៥ មាននិស្ស័យជួបគ្នានៅកន្លែងធ្វើការ ហើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ប្រសូតបានកូនស្រីមួយ។ ដូច្នេះហើយឥលូវនេះ នៅក្នុងគ្រួសាររបស់ខ្ញុំ គឺប្រតិបត្តិការបង្រៀន (គិតអ្នកដទៃជាចំបូង) ហើយសម្រាប់ខ្ញុំការទំនាក់ទំនងជាមួយភរិយានិងកូនស្រីវាសំខាន់ណាស់។ ភាពជាក់លាក់ ខ្ញុំបានទទួលការនៃនាំលោកគ្រូប្រធាន គឺបានប្រតិបត្តិការឆ្លើយតបដោយពាក្យ (បាទ) ហើយបាននប្រើប្រាស់ពាក្យពេជន៍គួរសមជានិច្ច។ ដូច្នេះម្ដងម្កាល ពេលសន្ទនាជាមួយភរិយា មិនបានឆ្លើយពាក្យ(បាទ) បានឆ្លើយថា( អឺៗ) ពេលនោះកូនស្រីខ្ញុំបាននៃនាំមកខ្ញុំថា ប៉ា កុំឆ្លើយ(អឺ) គឺឆ្លើយបាទបានល្អ។

ជាដំបូង ខ្ញុំគិតថាចង់បង្រៀនប្រពន្ធនិងកូនស្រីខ្ញុំ ពីពាក្យ(គិតអ្នកដទៃជាចំបូង) ពួកគាត់កំពុងតែប្រតិបត្តិ ហើយថ្មីៗ ប្រពន្ធនិងកូនស្រីខ្ញុំពួកគាត់តែងតែនឹកឃើញមានចិត្ត(គិតអ្នកដទៃ) ពិតជាគួរអោយអរគុណ។

ដូចដែលបាននិយាយរៀបរាប់ដូចខាងដើម បច្ចុប្បន្នខ្ញុំកំពុងបំរើការនៅក្រុមហ៊ុនអចលនទ្រព្យរបស់ជប៉ុន ។

ជារៀងរាល់ថ្ងៃពិតជាមានការរវល់ខ្លាំង ប៉ុន្តែ អារម្មណ៍បំពេញការងារមានជានិច្ច ដោយសារការខំប្រឹងប្រែងខ្ញុំបានទទួលប្រាក់បៀវត្តន៍យ៉ាងសមរម្យ។ ខ្ញុំព្យាយាមធ្វើអោយជីវិតរបស់ខ្ញុំយ៉ាងសាមញ្ញ ប្រាក់ខែមួយផ្នែក បានយកទិញដីប្រើប្រាស់ជិតផ្ទះនៅខេត្តបាត់ដំបង។ ដោយសារការខំប្រឹងប្រែង ពេលនេះខ្ញុំមានដីកាន់កាប់យ៉ាងធំល្វឹងល្វើយ។

ជាប្រភេទដីកសិកម្ម មានកម្មករជាច្រើននាក់កំពុងធ្វើការអោយខ្ញុំ នៅពេលខែប្រមូលផលខ្ញុំបានសុំច្បាប់លោកនាយក ទៅមើលចំការតាមដែលអាចធ្វើទៅបានដើម្បីចូលរួមធ្វើការជាមួយកម្មករ។ លើសពីនេះទៅទៀតខ្ញុំមានបំណងពង្រីកដីចំការអោយធំ ដើម្បីបង្កើតការងារអោយច្រើនសម្រាប់អ្នកនៅតំបន់នោះ ។ ខ្ញុំតែងតែគិតថា ធ្វើអោយជីវិតខ្ញុំមានជីវភាពស្ថេរភាព។ ហើយនៅទីបញ្ចប់ មានបំណងសាងសង់សាលានៅក្នុងកសិដ្ឋាន ដើម្បីកូនៗរបស់

បុគ្គលិកកម្មករទទួលបានការអប់រំយកធទៅប្រើប្រាស់ជាសកល ហើយខ្ញុំសង្ឃឹមថាវាដើរតួរយ៉ាងសំខាន់ដើម្បីសេចក្តីសុខសុភមង្គលរបស់ប្រជាជនខ្មែរ ក្រោពីយើងមានធនធានមនុស្សល្អៗ ខ្ញុំគិតថានឹងនៅបន្តការលះបង់របស់ខ្ញុំតទៅទៀត។

ជីវិតរបស់ខ្ញុំបានផ្លាស់ប្តូរដោយសារការបង្រៀននូវ (គិតអ្នកដទៃចំបូង)

ខ្ញុំសូមថ្លែងនូវសេចក្តីដឹងគុណយ៉ាងជ្រាលជ្រៅចំពោះលោកប្រធានស្ថាបនិក ដែលបានទុកការបង្រៀននេះដល់ពួកយើង ។ ការសម្តែងរបស់សូមបញ្ចប់ត្រឹមតែប៉ុណ្ណេះ ! សូមអរគុណច្រើនចំពោះអ្នកទាំងអស់គ្នា៕



*ជាមួយសមាជិកគ្រួសារ (ភ្នំពេញ)*

# Rissho Kosei-kai: A Global Buddhist Movement




**Rissho Kosei-kai Buddhist Church of Hawaii**
2280 Auhuhu Street, Pearl City, HI 96782, USA
TEL: 1-808-455-3212 FAX: 1-808-455-4633
Email: sangha@rkhawaii.org URL: http://www.rkhawaii.org

**Rissho Kosei-kai Maui Dharma Center**
1809 Nani Street, Wailuku, HI 96793, USA
TEL: 1-808-242-6175 FAX: 1-808-244-4625

**Rissho Kosei-kai Kona Dharma Center**
73-4592 Mamalahoa Highway, Kailua-Kona, HI 96740, USA
TEL: 1-808-325-0015 FAX: 1-808-333-5537

**Rissho Kosei-kai Buddhist Center of Los Angeles**
2707 East First Street, Los Angeles, CA 90033, USA
TEL: 1-323-269-4741 FAX: 1-323-269-4567
Email: rk-la@sbcglobal.net URL: http://www.rkina.org/losangeles.html

Please contact Rissho Kosei-kai Buddhist Center of Los Angeles
**Rissho Kosei-kai Buddhist Center of Arizona**
**Rissho Kosei-kai Buddhist Center of Colorado**
**Rissho Kosei-kai Buddhist Center of San Diego**
**Rissho Kosei-kai Buddhist Center of Las Vegas**
**Rissho Kosei-kai Buddhist Center of Dallas**

**Rissho Kosei-kai of San Francisco**
(Address) 1031 Valencia Way, Pacifica, CA 94044, USA
(Mail) POBox 778, Pacifica, CA 94044, USA
TEL: 1-650-359-6951 Email: lotusbuddhist@gmail.com
URL: https://sf-buddhism.org/

Please contact Rissho Kosei-kai of San Francisco
**Rissho Kosei-kai of Sacramento**
**Rissho Kosei-kai of San Jose**

**Rissho Kosei-kai of New York**
320 East 39th Street, New York, NY 10016, USA
TEL: 1-212-867-5677 Email: rkny39@gmail.com URL: http://rk-ny.org

**Rissho Kosei-kai of Chicago**
1 West Euclid Ave., Mt. Prospect, IL 60056, USA
TEL: 1-773-842-5654
Email: murakami4838@aol.com URL: http://rkchi.org

**Rissho Kosei-kai of Fort Myers**
URL: http://www.rkftmyersbuddhism.org

**Rissho Kosei-kai Dharma Center of Oklahoma**
(Address) 2745 N.W. 40th St., Oklahoma City, OK 73112, USA
(Mail) POBox 57138, Oklahoma City, OK 73157, USA
TEL: 1-405-943-5030 FAX: 1-405-943-5303
Email: rkokdc@gmail.com URL: http://www.rkok-dharmacenter.org

**Rissho Kosei-kai Dharma Center of Dayton**
617 Kling Drive, Dayton, OH 45419, USA
URL: http://www.rkina-dayton.com

**The Buddhist Center Rissho Kosei-kai International of North America (RKINA)**
2707 East First St., Suite #1, Los Angeles, CA 90033, USA
TEL: 1-323-262-4430 FAX: 1-323-269-4567
Email: info@rkina.org
URL: https://www.buddhistcenter-rkina.org

**Rissho Kosei-kai of Vancouver**
Please contact RKINA

**Rissho Kosei-kai International**

**Rissho Kosei-kai Buddhist Center of San Antonio**
(Address) 6083 Babcock Road, San Antonio, TX 78240, USA
(Mail) POBox 692148, San Antonio, TX 78249, USA
TEL: 1-210-558-4430 FAX: 1-210-696-7745
Email: dharmasanantonio@gmail.com
URL: http://rksabuddhistcenter.org

**Rissho Kosei-kai of Seattle's Buddhist Learning Center**
28621 Pacific Highway South, Federal Way, WA 98003, USA
TEL: 1-253-945-0024 Email: rkseattlewashington@gmail.com
URL: http://buddhistlearningcenter.org

**Risho Kossei-kai do Brasil**
Rua Dr. José Estefno 40, Vila Mariana, São Paulo-SP, CEP 04116-060, Brasil
TEL: 55-11-5549-4446, 55-11-5573-8377
Email: risho@rkk.org.br URL: http://www.rkk.org.br

**在家佛教韓国立正佼成会　Korean Rissho Kosei-kai**
〒 04420 大韓民国 SEOUL 特別市龍山區漢南大路 8 路 6-3
6-3, 8 gil Hannamdaero Yongsan gu, Seoul, 04420, Republic of Korea
TEL: 82-2-796-5571　FAX: 82-2-796-1696

**在家佛教韓国立正佼成会釜山支部**
**Korean Rissho Kosei-kai of Busan**
〒 48460　大韓民国釜山廣域市南區水營路 174, 3F
3F, 174 Suyoung ro, Nam gu, Busan, 48460, Republic of Korea
TEL: 82-51-643-5571　FAX: 82-51-643-5572

**社團法人在家佛教立正佼成會　Rissho Kosei-kai of Taipei**
台湾台北市中正區衡陽路 10 號富群資訊大厦 4 樓
4F, No. 10, Hengyang Road, Jhongjheng District, Taipei City 100, Taiwan
TEL: 886-2-2381-1632, 886-2-2381-1633　FAX: 886-2-2331-3433

**台南市在家佛教立正佼成會　Rissho Kosei-kai of Tainan**
台湾台南市東区崇明 23 街 45 號
No. 45, Chongming 23rd Street, East District, Tainan City 701, Taiwan
TEL: 886-6-289-1478　FAX: 886-6-289-1488
Email: koseikaitainan@gmail.com

**Rissho Kosei-kai South Asia Division**
Thai Rissho Friendship Foundation
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang, Bangkok 10310, Thailand
TEL: 66-2-716-8141　FAX: 66-2-716-8218

**Rissho Kosei-kai of Kathmandu**
Ward No. 3, Jhamsikhel, Sanepa-1, Lalitpur, Kathmandu, Nepal

**Rissho Kosei-kai Society of Kolkata**
89 Srirampur Road (VIP), Garia, Kolkata 700084, India

**Rissho Kosei-kai of Kolkata North**
AE/D/12 Arjunpur East, Teghoria, Kolkata 700059,
West Bengal, India

**Rissho Kosei-kai of Bodhgaya Dharma Center**
Ambedkar Nagar, West Police Line Road, Rampur, Gaya-823001,
Bihar, India

**Rissho Kosei-kai of Patna Dharma Center**
Please contact Rissho Kosei-kai Society of Kolkata

**Rissho Kosei-kai of Central Delhi**
77 Basement D.D.A. Site No. 1, New Rajinder Nagar,
New Delhi 110060, India

**Rissho Kosei-kai of Singapore**
Please contact Rissho Kosei-kai International

**Rissho Kosei-kai of Phnom Penh**
W.C. 73, Toul Sampaov Village, Sangkat Toul Sangke, Khan Reouseykeo,
Phnom Penh, Cambodia

**RKISA Rissho Kosei-kai International of South Asia**
Thai Rissho Friendship Foundation
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang, Bangkok 10310, Thailand
TEL: 66-2-716-8141　FAX: 66-2-716-8218

**Rissho Kosei-kai of Bangkok**
Thai Rissho Friendship Foundation
201 Soi 15/1, Praram 9 Road, Bangkapi, Huaykhwang, Bangkok 10310, Thailand
TEL: 66-2-716-8216　FAX: 66-2-716-8218　Email: info.thairissho@gmail.com

**Rissho Kosei Dhamma Foundation**
No. 628-A, Station Road, Hunupitiya, Wattala, Sri Lanka
TEL: 94-11-2982406　FAX: 94-11-2982405

**Rissho Kosei-kai of Polonnaruwa**
Please contact Rissho Kosei Dhamma Foundation

**Rissho Kosei-kai Bangladesh**
85/A Chanmari Road, Lalkhan Bazar, Chittagong, Bangladesh
TEL: 880-2-41360470

**Rissho Kosei-kai Mayani**
Mayani Barua Para, Mirsarai, Chittagong, Bangladesh

**Rissho Kosei-kai Damdama**
Damdama Barua Para, Mirsarai, Chittagong, Bangladesh

**Rissho Kosei-kai Satbaria**
Village: Satbaria Bepari Para, Chandanaih, Chittagong, Bangladesh

**Rissho Kosei-kai Chendhirpuni**
Village: Chendhirpuni, P.O.: Adhunogar, P.S.: Lohagara, Chittagong,
Bangladesh

**Rissho Kosei-kai Raozan**
Dakkhin Para, Ramzan Ali Hat, Raozan, Chittagong, Bangladesh

**Rissho Kosei-kai Laksham**
Village: Dhupchor, Laksham, Comilla, Bangladesh

**Rissho Kosei-kai Dhaka North**
408/8 DOSH, Road No 7 (West), Baridhara, Dhaka, Bangladesh

**Rissho Kosei-kai Cox's Bazar**
Ume Burmize Market, Tekpara, Sadar, Cox's Bazar, Bangladesh

Please contact Rissho Kosei-kai Bangladesh
**Rissho Kosei-kai Patiya**
**Rissho Kosei-kai Ramu**
**Rissho Kosei-kai Aburkhil**

**Buddiyskiy khram "Lotos"**
4 Gruzinski Alley, Yuzhno-Sakhalinsk 693005, Russia
TEL: 7-4242-77-05-14

**Rissho Kosei-kai of Hong Kong**
Flat D, 5/F, Kiu Hing Mansion, 14 King's Road, North Point, Hong Kong, China

**Rissho Kosei-kai Friends in Shanghai**
Please contact Rissho Kosei-kai International

**Rissho Kosei-kai of Ulaanbaatar**
(Address) 15F Express Tower, Peace avenue, khoroo-1, Chingeltei district,
Ulaanbaatar 15160, Mongolia
(Mail) POBox 1364, Ulaanbaatar-15160, Mongolia
TEL: 976-70006960　Email: rkkmongolia@yahoo.co.jp

**Rissho Kosei-kai of Erdenet**
Please contact Rissho Kosei-kai International

**Rissho Kosei-kai di Roma**
Via Torino, 29, 00184 Roma, Italia
TEL/FAX: 39-06-48913949　Email: roma@rk-euro.org

Please contact Rissho Kosei-kai di Rome
**Rissho Kosei-kai of Paris**
**Rissho Kosei-kai of Venezia**

**Rissho Kosei-kai of the UK**
29 Ashbourne Road, London W5 3ED, UK
TEL: 44-20-8933-3247　Email: info@rkuk.org　URL: https://www.rkuk.org
Facebook: https://www.facebook.com/rkuk.official
Twitter: https://twitter.com/rkuk_official
Instagram: https://www.instagram.com/rkuk_official

**Rissho Kosei-kai International Buddhist Congregation (IBC )**
166-8537　東京都杉並区和田 2-7-1　普門メディアセンター 3F
Fumon Media Center 3F, 2-7-1 Wada, Suginami-ku, Tokyo 166-8537, Japan
TEL: 03-5341-1230　FAX: 03-5341-1224　URL: http://www.ibc-rk.org

**Published by Rissho Kosei-kai International**